01389698

002/19-09-2007-ECCC/TC
E1/508

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10/02/2017
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

### សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

### ថ្ងៃ ពុធ ទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦

### សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៨៩

រៀបចំដោយ៖ លោក ឯម ហ៊ិយ និង Mr. Harshan ATHURELIYA

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ិយ, Mr. Harshan ATHURELIYA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, Mr. Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វណ្ណល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marrie Guiraud, លោក ហុង គីមសួន, លោកស្រី ស៊ិន សុវ៉ន |
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ សាក្សី នួន ត្រិច ហៅ ទេសត្រិច (2-TCW-1060) |

| |
|---|
| មេធាវីប្រឹក្សាសាក្សី៖ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី ស្នូរ សុទ្ធាវី |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, Ms. Elodie KANCEL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖ ១១.០៨ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ២ ម៉ោង និង ៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ, ក្រឡាបញ្ជី | ០៩.០៣ | ០៩.០៤ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៤ | ០៩.០៦ |
| ការតាំងសំណួរទៅសាក្សី នួន ត្រិច (2-TCW-1060) | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦<br>០៩.២៣<br>០៩.៤៨ | ០៩.២៣<br>០៩.៤៧<br>១០.០៧ |
| សារណាផ្ទាល់មាត់ស្តីពីសំណើសុំទទួលយកឯកសារពាក់ព័ន្ធទៅនឹងអ្នកជំនាញ 2-TCE-1062 អនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។ | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ | ១០.១១<br>១០.១៤<br>១០.១៤<br>១០.១៥<br>១១.០២ | ១០.១៤<br>១០.១៤<br>១០.១៥<br>១០.១៦<br>១១.០២ |
| សារណាផ្ទាល់មាត់ស្តីពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-237 (ស សារិន) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា | ១០.១៧<br>១០.៣១<br>១០.៣៧ | ១០.៣០<br>១០.៣៧<br>១០.៤៣ |

| | | | |
|---|---|---|---|
| | សហមេធាវីនាំមុខ | ១០.៤៣ | ១០.៤៨ |
| | អង្គជំនុំជម្រះ | ១០.៥៣ | ១០.៥៥ |
| | មេធាវីការពារក្តី ខៀវ សំផន | ១០.៥៨ | ១១.០២ |
| | អង្គជំនុំជម្រះ | ១១.០៥ | ១១.០៧ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅកាន់ សាក្សី នួន គ្រិច (2-TCW-1060)**

សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅសាក្សី នួន គ្រិច (2-TCW-1060)។

**សារណាផ្ទាល់មាត់ស្តីពីសំណើសុំឱ្យទទួលយកឯកសារទាក់ទងទៅនឹងអ្នកជំនាញ 2-TCE-1062**

អង្គជំនុំជម្រះបានស្តាប់សារណាអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យទទួលយកឯកសារចំនួន៣ ទាក់ទងទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-1062 ។ សហព្រះរាជអាជ្ញបានបញ្ជាក់ថា ឯកសារចំនួន ២ ដំបូង មានផ្ទុកនូវពត៌មានបន្ថែមទាក់ទងទៅនឹងការសិក្សាទៅលើសាកសពនៅជើងឯក ហើយឯកសារទាំងនោះនឹងត្រូវបានប្រើប្រាស់សម្រាប់សួរដេញដោលអ្នកជំនាញ ។ សហព្រះរាជអាជ្ញា បានពិចារណាទៅលើការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ (2-TCW-906) សាក្សី មន្ទីរសន្តិសុខ ស-២១ ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ មេធាវីការពារក្តី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានជំទាស់ទៅនឹងសំណើនេះទេ។ មេធាវីការពារក្តី ខៀវ សំផន មិនមានការជំទាស់ទេ ដោយហេតុថា បើតាមចម្លើយរបស់ សាក្សី ស៊ឹម ហ៊ុយ (2-TCW-906) ដែលបានផ្តល់ជូនអង្គជំនុំជម្រះ និងចម្លើយពីមុនមកគឺគ្មានអ្វីថ្មីនោះទេ ។ អង្គជំនុំជម្រះបានបញ្ជាក់ថា សេចក្តីសម្រេច

នេះ នឹងចេញនៅពេលខាងមុខឆាប់ៗនេះ។

<u>សារណាផ្ទាល់មាត់ ស្តីពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-TCCP-237)</u>

អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់ទៅលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ទាក់ទងទៅនឹងភស្តុតាងដាក់បន្ទុកដែលមាននៅក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-TCCP-237) ដែលដើមបណ្តឹងរូបនេះ មិនបានបញ្ចប់សក្ខីកម្មរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-TCCP-237) មកកាន់តុលាការដើម្បីឱ្យគាត់បញ្ចប់សក្ខីកម្មរបស់គាត់ ឬ បើមិនដូច្នេះទេ ចំពោះសក្ខីកម្មរបស់គាត់ដែលបានផ្តល់រួចហើយ ត្រូវលុបចោល ឬ ចាត់ទុកថាមិនអាចប្រើប្រាស់បាន ដោយលើកឡើងថា មេធាវីការពារក្តីមិនត្រូវបានផ្តល់ឱកាសឱ្យធ្វើការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះ មិនអាចយកមកពិចារណាចំពោះសក្ខីកម្មរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-CCP-237) នោះទេ។

សហព្រះរាជអាជ្ញា បានកត់សម្គាល់ថា សារណាអំពីការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-CCP-237) គួរត្រូវបានដាក់ជាលាយលក្ខណ៍អក្សរ ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ប្រសិនបើមេធាវីការពារក្តីមិនមានឱកាសសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-CCP-237) នោះ សក្ខីកម្មនៅក្នុងតុលាការ និងកិច្ចសម្ភាសន៍របស់ DC-Cam ដែលមានពីមុនមក គួរត្រូវបានចាត់ទុកថាជាចម្លើយដែលមិនបានមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា ខ្លួនពុំមានលទ្ធភាពដើម្បីបង្ខំដើមបណ្តឹងរដ្ឋប្បវេណីឱ្យមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ឬ លុបចោលសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-CCP-237) បានទេ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងទៀតថា មេធាវីការពារក្តីមានឱកាសប្តឹងសារទុក្ខ ប្រសិនខ្លួនជឿជាក់ថា សក្ខីកម្មរបស់គាត់ត្រូវបានយកទៅប្រើប្រាស់លើសលុប។ ចៅក្រមឡាវែងចង់ដឹង ថាតើដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-CCP-237) នៅតែចង់រក្សាឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដដែលឬយ៉ាងណា។

ប្រធានអង្គជំនុំជម្រះ ស្នើឱ្យភាគីដាក់សារណាជាលាយលក្ខណ៍អក្សរ អំពីការប្រើប្រាស់ភស្តុតាង (ជាពិសេស ភស្តុតាងដាក់បន្ទុក) ដែលបានផ្តល់សក្ខីកម្មដោយដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-CCP-237)។

**Reclassified**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/7537 | - | 00019638-00019658; 00251247-00251264; 00290995-00291017 | DC-Cam: Interview with Tel Ol aka Pheak or Tes Trich | P | 00019644; 00019645; 00019648; 00019649 | 00251252; 00251253; 00251256 | 00291001; 00291002; 00291006; 00291007 |
| E3/7877.1 | D231/24R | 01357613; - 01358654 | Transcript of Interview of TES Trech | P | 01357613 | - | 01358654 |

<u>**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៦)
- សេចក្ដីសម្រេចផ្ទាល់មាត់ទៅលើសារណាទាក់ទងទៅនឹងភ័ស្តុតាង ដែលបានផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន (2-CCP-237) នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ។ (១១.០៣)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹកនៅថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ។ (១១.០៨ )

<u>**កាលវេលាសវនាការបន្ត**</u>

សវនាការនឹងបន្តទៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃ... ២០១៦

ក្រឡាប... ក្រឡាបញ្ជី

លោក **ឯម ហ៊ុយ** ... Harshan ATHURELIYA